## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៦

## ការប្រកួតរូបថត ″ជប៉ុននៅកម្ពុជា″

ស្ថានទូតជប៉ុន មានសេចក្តីរីករាយសូមជូនដំណឹងអំពីការប្រកួតរូបថតលើកទី១ ក្រោមប្រធានបទ ″ **ជប៉ុននៅកម្ពុជា**″ គឺជាអ្វីៗដែលអ្នកយល់ និង គិតថាជាទម្រង់លក្ខណៈបែបជប៉ុននៅក្នុងប្រទេសកម្ពុជា។

**កាលបរិច្ឆេទផុតកំណត់**

ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១៦

**ការជ្រើសរើស និង រង្វាន់**

- ស្ថានទូតនឹងជ្រើសយករូបថត៣សន្លឹកដែលល្អផ្តាច់គេ។ រូបថតដែលថតបានល្អ និងប្លែកពីគេ នឹងទទួលបានការវាយតម្លៃខ្ពស់។ និតិវិធីក្នុងការជ្រើសរើសនឹងមិនជម្រាបជូនទេ។

- រូបថតដែលទទួលបានជ័យលេខភី នឹងត្រូវដាក់បង្ហាញលើទំព័រហ្វេសប៊ុករបស់ស្ថានទូតនៅថ្ងៃទី១៦ ខែកញ្ញា។

- ព័ត៌មានផ្ទាល់ខ្លួនដែលបានបំពេញក្នុងពាក្យសុំប្រកួតរបស់អ្នកទទួលបានជ័យលាភីដូចជាឈ្មោះ សញ្ជាតិ ចំណាងជើង ព្រមទាំងការពន្យល់ខ្លឹមសារ និង ទីតាំងថតរូប នឹងត្រូវបង្ហាញជាមួយរូបថត ព្រមទាំងអត្ថបទបកប្រែ និងកែសម្រួល ។

- ជ័យលាភីលេខ១ នឹងទទួលបានម៉ាស៊ីនថតផ្តិតរូបបានភ្លាម ម៉ាក "Instax mini 8" មួយគ្រឿង។

- ជ័យលាភីលេខ២ នឹងទទួលបាន external hard disk drive មួយ។

- ជ័យលាភីលេខ៣ នឹងទទួលបាន portable battery charger មួយ ។

**លក្ខណ្ឌនៃការចុះឈ្មោះ**

- បេក្ខជនទាំងកម្ពុជា និង ជនបរទេស ដែលស្នាក់នៅប្រទេសកម្ពុជាស្របច្បាប់ និងមានអាយុលើសពី១២ឆ្នាំឡើងទៅ អាចចូលរួមប្រកួតបាន លើកលែងតែ អ្នកថតរូបអាជីព និង អ្នកសារព័ត៌មាន។

- រូបថត JPEG ដែលមានទំហំចាប់ពី70KB-300KB។

- រូបថតត្រូវតែជារូបដែលមិនចម្លងពីគេ។ សូមផ្ញើរូបថតណាដែលមិនធ្លាប់បានចូលរួម និង មិនមានគម្រោងចូលរួមក្នុងការប្រកួតដទៃទៀត។

- បេក្ខជនត្រូវតែច្បាស់លាស់អំពីកម្មសិទ្ធិបញ្ញានៃរូបថតរបស់ខ្លួន មុនដាក់ពាក្យប្រកួត។ រូបថតដែលផ្តិតជាប់បុគ្គលណាម្នាក់ នោះបេក្ខជនត្រូវតែទទួលបានការអនុញ្ញាតពីបុគ្គលនោះសិន។
- មិនត្រូវប្រើរូបថតដែលមានការកែច្នៃនោះទេ។
- សូមផ្ញើរូបថតដែលបានថតត្រឹម ឬ ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ ២០១៦។
- សូមផ្ញើរូបថតជាមួយពាក្យសុំប្រកួត តាមរយៈសារអេឡិចត្រូនិច (E-mail) ទៅកាន់ info.jpn@pp.mofa.go.jp ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ផ្នែកវប្បធម៌ និង ព័ត៌មាន តាមរយៈលេខទូរស័ព្ទ០២៣ ២១៧ ១៦១ ឬ info.jpn@pp.mofa.go.jp។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162*

*Email: (info.jpn@pp.mofa.go.jp)*

*Official Website: www.kh.emb-japan.go.jp*